International Labour Organization

better factories Cambodia

# អង្គការពលកម្មអន្តរជាតិ (ILO) និង កម្មវិធីរួមដើម្បីកុមារ សន្តិសុខស្បៀង និងអាហាររូបត្ថម្ភនៅកម្ពុជា នៃមូលនិធិគោលដៅអភិវឌ្ឍន៍សហសវត្សន៍ (MDG-F)

ការដោះស្រាយបញ្ហាដែលទាក់ទិនទៅនឹងកុមារ សន្តិសុខស្បៀង និង អាហារូបត្ថម្ភតាមរយៈដៃគូពាក់ព័ន្ធរបស់អង្គការ ILO (រដ្ឋាភិបាល សហជីព និង និយោជក) គឺជាវិធីដ៏ល្អមួយ នៅក្នុងការធ្វើអោយប្រសើរឡើង នូវការគាំពារមាតុភាព និងសុខភាពនៅកន្លែងធ្វើការ ដើម្បីប្រយោជន៍រួមទាំងភាគីកម្មករនិយោជិត និយោជក និង សង្គមទាំងមូល ។

តាមរយៈ MDG-F អង្គការពលកម្មអន្តរៈជាតិធ្វើការសហការជាមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និយោជក និង សហជីព និង ក្រោមការផ្តើមគំនិតតាមរយៈ*កម្មវិធីនៃរោងចក្រកាន់តែប្រសើរនូវកម្ពុជា* (BFC) ដើម្បីធ្វើការជាមួយនឹង ស្ត្រី និងបុរស ដែលធ្វើការនៅក្នុងរោងចក្រកាត់ដេរ និង វិស័យសណ្ឋាគារ ក្នុងការធ្វើអោយប្រសើរឡើងនូវលក្ខខ័ណ្ឌការងារការគាំពារមាតុភាព និងបន្តការថែទាំសុខភាពដល់កម្មករនិយោជិត ។ កម្មវិធីនេះមានគោលបំណងជាការគាំទ្រ និងធ្វើអោយមានបរិយាកាសល្អទៅលើផ្នែកដូចខាងក្រោមៈ

- គោលនយោបាយនៅកន្លែងការងារ និង ការតស៊ូមតិ អាចពង្រឹងនូវការផ្លាស់ប្តូរឥរិយាបទទំនាក់ទំនងនៅកន្លែងការងារ ។
- គោលនយោបាយ ដែលអាចធ្វើអោយស្ត្រីបំពេញការងារ អាចឈប់សំរាកលំហែមាតុភាពមុន នឹងក្រោយពេលសំរាលកូន ត្រូវបានអនុវត្តបានយ៉ាងទៀងទាត់នៅកន្លែងការងារ ។ នេះគឺជាការចាំបាច់សំរាប់សុខភាពរបស់ម្តាយ និងទារក និង សំរាប់ផ្តល់នូវការអនុវត្តន៏ការបំបៅកូនដោយទឹកដោះដែលមានសារៈប្រយោជន៏ចំពោះសុខភាព និងអាហាររូបត្ថម្ភរបស់ក្មេង ។
- នៅពេលដែលពួកគាត់ត្រឡប់ចូលមកធ្វើការវិញ ការគាំទ្រត្រូវបានបង្កើតអោយមានការសំរាកបំបៅកូនដោយទឹកដោះ កន្លែងសមរម្យ និងការទទួលដំបូន្មានបានត្រឹមត្រូវ ធ្វើអោយមានការបំបៅកូនដោយទឹកដោះ យ៉ាងហោចណាស់អោយបានចំនួន ៦ ខែ យោងតាមការណែនាំដោយ អង្គការសុខភាពពិភពលោក (WHO) ។
- លទ្ធភាពត្រឡប់មកធ្វើការវិញដោយពុំចាំបាច់លះបង់ការបំបៅកូន ត្រូវបានធ្វើអោយប្រសើរឡើង ដើម្បីលើកស្ទួយការគាំពារដល់អាហាររូបត្ថម្ភ និងសុខភាពកុមារអោយកាន់តែប្រសើរ ។

## ការគាំពារមាតុភាព

ការគាំពារមាតុភាពត្រូវបានគេចាត់ទុកជាបញ្ហាចំបងមួយសំរាប់រដ្ឋជាសមាជិករបស់អង្គការពលកម្មអន្តរៈជាតិ (ILO) ចាប់តាំងពីការកើតឡើងមកម្លេះ ។ យោងលើប្រវត្តិសាស្ត្ររបស់ខ្លួន អនុសញ្ញាបីស្តីពីការគាំពារមាតុភាពត្រូវបានបង្កើតឡើង ( អនុសញ្ញាលេខ ៣ នៅឆ្នាំ ១៩១៩ អនុសញ្ញាលេខ ១០៣ នៅឆ្នាំ ១៩៥២ អនុសញ្ញាលេខ ១៨៣ នៅឆ្នាំ ២០០០ ) ដែលបាននឹងកំពុងពង្រីកវិសាលភាព និងសិទ្ធិផ្សេងៗនៃការគាំពារមាតុភាពនៅកន្លែងការងារ ។ ការព្រួយបារម្ភជាចំបងត្រូវធានាអោយប្រាកដថា ការងាររបស់ស្ត្រី មិនមានការគំរាមកំហែងដល់សុខភាពរបស់ស្ត្រី ឬ កុមារ នៅក្នុងកំឡុងពេល និងបន្ទាប់ពីមានគតិ និងធានាថា មុខនាទីបន្តពូជរបស់ស្ត្រី មិនត្រូវទទួលនូវផលប៉ះពាល់ដោយមូលហេតុ សេដ្ឋកិច្ច និងការបំពេញការងាររបស់ខ្លួនឡើយ ។[១] គោលការណ៏ចំបងនៃ ការគាំពារមាតុភាពរួមមានវិសាលភាពនៃការគាំពារមាតុភាព សិទ្ធិទទួលបានការឈប់សំរាក ផលប្រយោជន៏ផ្សេងៗ ការការពារសុខភាព ការការពារការងារ ការសំរាកបំបៅកូន និងកន្លែងបំបៅកូនបានសមរម្យ ។

[១] See www.ilo.org/standards to see the full texts of the Conventions on maternity protection.

## ការគាំពារមាតុភាពនៅកន្លែងការងារ

អនុសញ្ញាស្តីពីការគាំពារមាតុភាព លេខ ១៨៣ ឆ្នាំ ២០០០ ផ្តល់នូវ :

- ការឈប់សំរាកលំហែមាតុភាពចំនួន ១៤ សប្តាហ៏សំរាប់រាប់បញ្ចូលទាំង ៦សប្តាហ៏សំរាប់ការឈប់សំរាកបន្ថែមបន្ទាប់ពីការផ្តល់កំណើតទារក
- ប្រយោជន៏ជាប្រាក់ដែលនៅក្នុងកំឡុងពេលឈប់សំរាក យ៉ាងហោចណាស់ពីរភាគបីនៃប្រាក់ចំនូលទាំងអស់ រឺប្រាក់ធានា ។
- ទទួលបានសេវាថែទាំសុខភាពពីពេទ្យ រាប់បញ្ចូលទាំងមុនពេលផ្តល់កំណើតទារក ការបង្កើតទារក និង បន្ទាប់ពីការផ្តល់កំណើតទារក ក៏ដូចជាកាស្នាក់នៅមន្ទីពេទ្យ នៅពេលមានករណីចាំបាច់ ។
- **ការការពារសុខភាព :** សិទ្ធិរបស់ស្ត្រីមានគតិ រឺ អ្នកថែរក្សាសុខភាពមិនត្រូវមានការរើសអើងចំពោះសុខភាពរបស់គេ និង កូនរបស់គេឡើយ ។
- **ការបំបៅកូនដោយទឹកដោះ:**យ៉ាងតិចអោយមានពេលសំរាកបំបៅកូន ១ ដងក្នុងមួយថ្ងៃ ដោយមានប្រាក់ឈ្នួល ។
- ការការពារដល់ការងារ និង គ្មានការរើសអើង ។

## ការគាំពារមាតុភាពនៅក្រោមច្បាប់ប្រទេសកម្ពុជា

រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាមានបញ្ញត្តិសំខាន់ៗទាក់ទិនទៅនឹងសិទ្ធិរបស់ស្ត្រី ។ ប្រទេសកម្ពុជាក៏បានទទួលស្គាល់អំពី កតិកាសញ្ញា និងអនុសញ្ញាជាច្រើនទៀតដែលការពារសិទ្ធិរបស់ស្ត្រីនៅកន្លែងការងារដូចជា អនុសញ្ញាស្តីពីការលុបបំបាត់រាល់ការរើសអើងប្រឆាំងនឹងស្ត្រី (CEDAW) ដែលហាមមិនអោយ មានការរើសអើសចំពោះស្ត្រី ដោយស្ថានភាពនៃការរៀបការ រឺ ដោយសារតែការមានគត៌ ។ មាត្រាទី៤៦នៃរដ្ឋធម្មនុញ្ញចែងថាស្ត្រីមិនគួរបាត់បង់ការងាររបស់ខ្លួនដោយសារតែមានគត៌នោះទេ ហើយគេគប្បីមានសិទ្ធិសំរាកសំរាលកូនដោយមានប្រាក់ឈ្នួលពេញ និងមិនបាត់បង់នូវអតីតភាពការងារ ឬប្រយោជន៏ផ្សេងៗនៃសង្គម ។

ច្បាប់ស្តីការងារនៃប្រទេសកម្ពុជាផ្តល់នូវការឈប់សំរាកលំហែមាតុភាពដោយមានប្រាក់ឈ្នួលដូចខាងក្រោមៈ

- ស្ត្រីមានសិទ្ធិឈប់សំរាកលំហែមាតុភាព ចំនួន ៩០ ថ្ងៃ ។
- ក្នុងកំឡុងពេល ២ ខែបន្ទាប់ពីត្រឡប់មកពីការឈប់សំរាកលំហែមាតុភាពវិញស្ត្រីត្រូវធ្វើការងារណាស្រាលៗប៉ុណ្ណោះ
- និយោជិតជាស្ត្រី មិនត្រូវបញ្ឈប់ពីការងារក្នុងពេលសំរាកមាតុភាពនោះទេ រឺ ក៏នៅក្នុងកាលវិច្ឆេទនៅចុងបញ្ចប់នៃការកាត់បន្ថយបុគ្គលិកក្នុងកំឡុងពេលឈប់សំរាកលំមៃាតុភាពនោះទេ ។
- នៅក្នុងកំឡុងពេលស្ត្រីឈប់សំរាកលំហែមាតុភាព គាត់ត្រូវទទួលបានប្រាក់ឈ្នួលពាក់កណ្តាលនៃប្រាក់ខែ និងផលប្រយោជន៏ផ្សេងៗជាសាច់ប្រាក់ និងធនលាភដទៃទៀតដ៏រាបណានិយោជិតនោះបានធ្វើការសំរាប់រយៈពេលមួយឆ្នាំដោយគ្មានអាក់ខាននៅក្នុងសហគ្រាស ។

## ការបំបៅដោះម្តាយនៅក្នុងប្រទេសកម្ពុជា

ការទទួលអាហាររូបត្ថម្ភមិនគ្រប់គ្រាន់ចំពោះក្មេង គឺ ជារឿយៗទាក់ទិនទៅនឹងរបៀបចិញ្ចឹមក្មេង និងទារកមិនបានត្រឹមត្រូវ ។ នៅទូទាំងពិភពលោកមានទារកតិចជាង ៦ ខែតែ ៣៤,៦%បានទទួលការចិញ្ចឹមដោះទឹកដោះម្តាយទាំងស្រុង ហើយអត្រានេះរាប់តាមលេខរៀងទៅមាន ៤៣,២% នៅក្នុងតំបន់អាស៊ីអាគ្នេយ៏ ហើយមានត្រឹមតែ ១៧,៧% នៅប៉ែកអ៊ឺរ៉ុប ។[២]

នៅក្នុងប្រទេសកម្ពុជា មានគោលនយោបាយទូលំទូលាយមួយ ដើម្បីបង្កើនអត្រានៃការការបំបៅដោះកូនដោយទឹកដោះ ។ ជាមធ្យម អត្រានៃការបំបៅកូនដោយទឹកដោះនៅក្នុងប្រទេសកម្ពុជា គឺ ៦០% នៅក្នុងប្រទេសកម្ពុជាចំពោះក្រុមទារកដែលមានអាយុ 0 ដល់ ៦ ខែ ។ ទោះជាយ៉ាងណាក៏ដោយ មានទារកតែ ៣៥% នៃទារកដែលទើបនឹងកើតប៉ុណ្ណោះដែលទទួលបានទឹកដោះម្តាយក្នុងរយៈពេល ១ ម៉ោងបន្ទាប់ពីសំរាលកូន និង មានទារក ២០%ដែលបានបៅដោះម្តាយនៅពេលដែលគេដល់អាយុ ៦ ខែ ។ មធ្យមភាគនៃការបំបៅកូនដោយទឹកដោះមានរយៈពេល ៣,២ ខែ និង ទារកភាគច្រើនទទួលអាហារបន្ថែមមុនពេលមានអាយុបាន ៤ ខែ ។[៣]

## ការងាររបស់គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជាទៅលើការគាំពារមាតុភាព និង ការបំបៅកូនដោយទឹកដោះ

អង្គការពលកម្មអន្តរៈជាតិ*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* *(BFC)* ត្រួតពិនិត្យទៅលើការអនុវត្តន៏ការគាំពារមាតុភាពដែលបានចែងក្នុង ច្បាប់ការងារនិងបានបង្កើតនូវ កម្មវីធីបង្រៀនផ្សេងៗ ជាច្រើនដើម្បីជួយសហគ្រាសធ្វើអោយប្រសើរឡើងចំពោះការគាំពារមាតុភាព។ ឧទាហរណ៏ដូចជា យើងបានផលិតជាខ្សែវីដេអូខ្លី ចំនួន ៨ ដែលបានបង្កើតឡើងដើម្បី បង្កើនចំណេះដឹងដល់កម្មករនិយោជិត អំពីសិទ្ធិ និងការទទួលខុសត្រូវរបស់ពួកគេ។ ខ្សែភាពយន្តខ្លីនេះត្រូវបានដាក់ បញ្ចាំងអោយកម្មករនិយោជិតមើលនៅក្នុងបរិវេណរោងចក្រដោយមានភ្ជាប់ជាមួយនៅ កូនសៀវភៅគំនូរជីវចលដែលមានអត្ថន័យដូចសាច់រឿងទាំងស្រុង ។វីដេអូខ្លីភាគទី ៥ ផ្តោតជាពិសេសទៅលើការសំរាកមាតុភាពនិងការបំបៅកូនដោយទឹកដោះ ។

## សារសំខាន់ៗនៅក្នុងវេដីអូខ្លីឃុតទី ៥:

- អ្នកមានសិទ្ធិក្នុងការឈប់សំរាលកូន
- ជាជំរើសដ៏ល្អបំផុតដែលម្តាយគ្រប់រូបបន្តបំបៅដោះកូនអោយបានយ៉ាងហោចណាស់ រយៈពេល ៦ ខែតំបូង
- កុំបំបៅទារកដោយទឹកដោះគោហ្វរមីឡាជំនួសទឹកដោះម្តាយ
- ច្បាប់បានចែងថា អ្នកអាចបំបៅកូននៅក្នុងម៉ោងធ្វើការបាន

សំរាប់ពត៏មានបន្ថែមសូមទាក់ទងមក ILO MDG-F - អ្នកសំរបសំរួលកម្មវិធី

លោក ជា សុផល អ៊ីម៉ែល sophal@ilo.org

អង្គការពលកម្មអន្តរៈជាតិ (ILO)នៃ

គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (BFC)

ផ្ទះលេខ ៩, សង្កាត់ បឹងកេងកង ១, ភ្នំពេញ,ប្រទេសកម្ពុជា

ទូរស័ព្ទ: ៨៥៥ ២៣ ២១២ ៨៤៧

ទូរសារ: ៨៥៥ ២៣ ២១២ 0៩៣

អ៊ីម៉ែល: betterfactories@ilo.org

គេហទំព័រ: www.betterfactories.org/ilo

---

[២] Black RE et al. Maternal and child undernutrition: global and regional exposures and health consequences. *Lancet*. 2008, 371(9608): 243–260.

[៣] National Institute of Public Health and National Institute of Statistics, 2006. *Cambodia Demographic Health Survey (CDHS) 2005 (revised in 2007)*.